**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការកែប្រែមាត្រា៧ នៃអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនភ្លើនគ្រេដ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនភ្លើនគ្រេដ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១.-**

មាត្រា៧ នៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនភ្លើនគ្រេដ ត្រូវបានកែប្រែទៅជា:

**មាត្រា៧ថ្មី.-**

ក្រុមហ៊ុនហ្គ្រីនត្រេដ (គ ម ត) ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ បទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈបុគ្គលិករបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាល មានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- អគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ | ១រូប | ជាប្រធាន |
| ២- តំណាងក្រសួងពាណិជ្ជកម្ម | ១រូប | ជាសមាជិក |
| ៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | ជាសមាជិក |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | ជាសមាជិក |
| ៥- តំណាងក្រសួងផែនការ | ១រូប | ជាសមាជិក |
| ៦- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | ជាសមាជិក |
| ៧- តំណាងនិយោជិករបស់ក្រុមហ៊ុនហ្គ្រីនត្រេដ | ១រូប | ជាសមាជិក |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ ២០០២

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ, កាលប្បវត្តិ